ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.ន.១២..០២១..០១២.ប្រកាសព័ត៌មាន

*ថ្ងៃចន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំរវាងប្រតិភូប្រទេសកម្ពុជា និងក្រុមការងារត្រួតពិនិត្យរួមនៃប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG-JG) ដែលប្រព្រឹត្តទៅ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ តាមរយៈ Videoconference

កាលពីថ្ងៃចន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ៩:០០ នាទីរសៀល អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរៀបចំកិច្ចប្រជុំតាមរយៈ Videoconference រវាងអាជ្ញាធរកម្ពុជាជាមួយក្រុមការងារត្រួតពិនិត្យរួមនៃប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG-JG) ដែលប្រព្រឹត្តទៅនៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍លើកទី៥ ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានដាក់ចេញ ដោយក្រុមការងារហិរញ្ញវត្ថុ (FATF) កាលពីថ្ងៃទី២២ ខែកុម្ភៈ ២០១៩។

នៅក្នុងកិច្ចប្រជុំនេះ ប្រតិភូតំណាងភាគីកម្ពុជា ដែលដឹកនាំដោយ លោកជំទាវ ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងតំណាងមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមមាន ទីស្តីការគណៈរដ្ឋមន្ត្រី ធនាគារជាតិនៃកម្ពុជា ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គស្នងការដ្ឋាននគរបាលជាតិ អង្គភាពប្រឆាំងអំពើពុករលួយ ព្រះរាជអាជ្ញា តុលាការ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ក្រុមប្រឹក្សាជាតិគណនេយ្យ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មានចំនួនប្រមាណ ៧០រូប។ ដោយឡែក សម្រាប់

ស.ហ.ក



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ក្រុមអ្នកវាយតម្លៃ មានសមាសភាពមកពីប្រទេស ចិន ឥណ្ឌា ជប៉ុន អាល្លឺម៉ង់ អាមេរិក បារាំង អង់គ្លេស អូស្ត្រាលី នូវែលសេឡង់ លេខាធិការដ្ឋាន APG លេខាធិការដ្ឋាន FATF និង គណៈកម្មាធិការសហភាពអឺរ៉ុប។ កិច្ចប្រជុំនេះត្រូវបានដឹកនាំដោយ សហប្រធានពីររូបគឺ លោក Yogpal Singh នៃប្រទេសឥណ្ឌា និង លោកស្រី Connie Chu នៃចិនម៉ាកាវ។

កិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំលើកទី៥ ដែលប្រតិភូប្រទេសកម្ពុជាបានធ្វើការរាយការណ៍ លើវឌ្ឍនភាពនៃការអនុវត្តសកម្មភាពដែលនៅដក់សល់ និងត្រូវបានទទួលការកោតសរសើរ ពីក្រុមការងារត្រួតពិនិត្យរួមនៃប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ លើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការបំពេញការងារជាច្រើន ស្របពេលដែលប្រទេស លើពិភពលោកកំពុងដោះស្រាយបញ្ហាជំងឺរាលដាល Covid-19។